កែទម្រង់ខាងក្នុង ពង្រីកមិត្តខាងក្រៅ ក្នុងស្មារតីឯករាជ្យ

យុវជនដើម្បីគណបក្ស គណបក្សដើម្បីយុវជននិងប្រទេសជាតិ

# គណបក្សប្រជាជនកម្ពុជា

**ឯករាជ្យ សន្តិភាព សេរីភាព**

**ប្រជាធិបតេយ្យ អព្យាក្រឹត និងវឌ្ឍនភាពសង្គម**

## ក្រុមការងារយុវជន
## គណបក្សប្រជាជនកម្ពុជា
## ប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**២០១៩**



ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល និងជាប្រធានគណៈកម្មាធិការគណបក្ស **កសហវ**



ឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** ប្រធាន **កយក** ប្រចាំ **កសហវ**

## សាវតារ

ការងារយុវជនគណបក្សក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) បានចាប់ផ្តើមអនុវត្ត ចាប់តាំងពីខែមេសា ឆ្នាំ២០១២ ដែលកាលនោះមានឈ្មោះថា “សកម្មជនយុវជនគណបក្ស”។ នៅក្នុងនីតិកាលទី៥ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល និងជាប្រធានគណៈកម្មាធិការគណបក្ស កសហវ បានណែនាំឱ្យពិនិត្យនិងកែសម្រួលយន្តការការងារ ឱ្យមានរចនាសម្ព័ន្ធគ្រប់គ្រងនិងការទទួលខុសត្រូវកាន់តែច្បាស់លាស់ ដើម្បីឆ្លើយតបនឹងតម្រូវការកម្លាំងយុវជន និងគាំទ្រយុវជនគណបក្ស។ ក្នុងន័យនេះ ជារចនាសម្ព័ន្ធគណៈកម្មាធិការគណបក្ស កសហវ មានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជា (កយក) ជាសេនាធិការ ដែលមានឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** ជាប្រធាន និងមានសមាជិកជាប្រធានក្រុមការងារយុវជននៅតាមសាខាបក្ស នៃអង្គភាពទាំង២១ ក្រោមឱវាទ កសហវ។

## សមិទ្ធផលនិងស្នាដៃ ប្រចាំឆ្នាំ ២០១៨

### ១. ការងារសម្រេចបាន

- បានរៀបចំបាឋកថាលើកទី២ ជូនយុវជននៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ ចំនួន ១០០០ រូប នៅទីស្នាក់ការ គ.៨៥ កាលពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៨
- បានរៀបចំបាឋកថាលើកទី៣ ជូនយុវជននៃទីស្តីការ កសហវ ចំនួន ១០០០ រូប នៅទីស្នាក់ការ គ.៨៥ កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨
- បានរៀបចំធ្វើបច្ចុប្បន្នភាពនិងបោះពុម្ពបន្ថែម សៀវភៅផែនការប្រតិបត្តិ ឆ្នាំ២០១៨ នៃ កយក ប្រចាំ កសហវ
- បានរៀបចំ ធ្វើបច្ចុប្បន្នភាព និងបោះពុម្ពបន្ថែមនូវខិតប័ណ្ណសម្រាប់ផ្សព្វផ្សាយសមិទ្ធផលសម្រេចបាន នៃ កយក ប្រចាំ កសហវ



ជំនួបសម្តែងការគួរសម ជូនចំពោះ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

- បានរៀបចំ សង្ខេប និងបោះពុម្ពផ្សាយ នូវសៀវភៅ “**ខ្លឹមសារគន្លឹះ÷ មាគ៌ាដឹកនាំ កម្មវិធីនយោបាយយុទ្ធសាស្ត្រ និងបទពិសោធន៍**”
- បានស្រង់ស្ថិតិយុវជនគណបក្ស នៅថ្នាក់កណ្តាលរបស់ កសហវ ដែលមានសរុបប្រមាណ ២០០០ រូប ក្នុងនោះ នារីមាន ៦៧០ រូប។



បទបាឋកថា ស្តីពីសាវតារ បុព្វហេតុ និងទស្សនវិស័យនយោបាយគណបក្សប្រជាជនកម្ពុជា និងគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាលកម្ពុជា

## ២. ការងារសម្រេចបានក្រៅផែនការ

- ជំនួបសម្តែងការគួរសម ជូនចំពោះ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** កាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨
- ជំនួបសម្តែងការគួរសម ជាមួយ **ឯកឧត្តមកិត្តិបរិរក្សបណ្ឌិត គាត ឈន់** កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨
- កិច្ចប្រជុំរវាង កយក ប្រចាំ កសហវ និង កយក ប្រចាំខេត្តបាត់ដំបង កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៨
- បានរៀបចំ “**សិក្ខាសាលាស្តីពីបុព្វហេតុ សមិទ្ធផល និងទស្សនវិស័យនៃការងារកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា**”។



បទបាឋកថា ជូនយុវជនគណបក្ស ប្រមាណ ១០០០ នាក់
ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមកិត្តិបរិរក្សបណ្ឌិត គាត ឈន់**

## ទិសដៅការងារបន្ត សម្រាប់ឆ្នាំ ២០១៩

- រៀបចំវីឌីអូស្តីពីសមិទ្ធផលសម្រេចបាន នៃ កយក ប្រចាំ កសហវ
- រៀបចំកម្មវិធីចុះជួយសហគមន៍ក្រីក្រតាមបណ្តារាជធានី-ខេត្ត
- រៀបចំវគ្គបណ្តុះបណ្តាលយុវជនឆ្នើមឱ្យក្លាយជាវាគ្មិនបង្គោល និងបំពេញមុខងារផ្សព្វផ្សាយបន្តគោលនយោបាយគណបក្ស
- រៀបចំបទបាឋកថារបស់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ជូនយុវជនគណបក្ស ប្រចាំ កសហវ
- រៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៩ របស់ កយក
- រៀបចំខិតប័ណ្ណដើម្បីផ្សព្វផ្សាយសមិទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៨ របស់ កយក ប្រចាំ កសហវ
- រៀបចំវិបស្សនាស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃ កយក ប្រចាំ កសហវ ដើម្បីរៀបចំផែនការសកម្មភាពរយៈពេល ៥ ឆ្នាំ។



កិច្ចប្រជុំរវាងលេខាធិការដ្ឋាន **កយក** ជាមួយ **ឯកឧត្តម វង្សី វិស្សុត**
សមាជិកគណៈកម្មាធិការកណ្តាល និងជាអនុប្រធានគណៈកម្មាធិការគណបក្ស **កសហវ**

### ទំនាក់ទំនង

ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជា
ប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

www.youth-cppmef.org